# របាយការណ៍សង្ខេបស្តីពីការវាយតម្លៃបឋមលើ
# សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល

ដោយកន្លងមក ការផលិតអំបិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានតែក្នុងខេត្តកែប និងខេត្តកំពត ហើយមុខរបរនេះមានតាំងពីយូរយាណាស់មកហើយ។ ម្យ៉ាងភាពប្រឈមនិងការទុកដីស្រែអំបិលឱ្យនៅទំនេឬកែប្រែទៅមុខសញ្ញាផ្សេងគឺកើតមានជារឿយៗ ដោយរដ្ឋាភិបាលនៅមិនទាន់មានយន្តការគ្រប់គ្រងច្បាស់លាស់និងជាប្រព័ន្ធនៅឡើយ។ ម្យ៉ាងទៀតសុវត្ថិភាព គុណភាព អំបិលនៅមានកម្រិតគួរឱ្យចាប់អារម្មណ៍ដោយកង្វះបច្ចេកទេសនិងការលើកទឹកចិត្តពីរាជរដ្ឋាភិបាល។

## ១. ការកំណត់បញ្ហា:

-នៅមិនទាន់មានយន្តការ នីតិវិធីគ្រប់គ្រងផលិតអំបិលច្បាស់លាស់នៅឡើយ

-ការវិចខ្ចប់នៅទាន់ធ្វើបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសនៅឡើយ

-អំបិលបរិភោគនៅមិនទាន់មានសារធាតុអ៊ីយ៉ូដគ្រប់គ្រាន់ (របាយការណ៍ UNICEF កាលពីឆ្នាំ២០១៥)

-កង្វះការចូលរួមពីសមត្ថកិច្ចជំនាញដើម្បីបង្កើនសមត្ថភាពបច្ចេកទេសនិងដោះស្រាយបញ្ហាប្រឈមនានាដល់ផលិតករអំបិល

-កង្វះទំនុកចិត្តពីអ្នកប្រើប្រាស់អំបិល

-មានការបង្វែរដីស្រែអំបិលទៅកម្មវត្ថុផ្សេង ឬទុកដីឱ្យនៅទំនេរ

## ២. គោលបំណង:

- កំណត់សមត្ថកិច្ចគ្រប់គ្រងស្រែអំបិលច្បាស់លាស់និងជាលក្ខណៈប្រព័ន្ធ
- លើកកម្ពស់គុណភាព ផលិតភាពអំបិល(តាមរយៈការផ្តល់លក្ខណៈបច្ចេកទេសនិងចូលរួមភាពអសកម្មនានា)
- ជួយជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈការបង្កទំនុកចិត្តពីអ្នកប្រើប្រាស់

## ៣. ជម្រើស:

១. រក្សាស្ថានភាពដើម

២. សំណើបញ្ញត្តិកម្មៈសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាកិច្ច និងផលចំណេញ

១. រក្សាស្ថានភាពដើមៈ

-រដ្ឋាភិបាលចំណាយអស់ទឹកប្រាក់ចំនួន ២,៤៤៩,២០០ ដុល្លាអាមេរិក

-ធុរជនចំណាយអស់ទឹកប្រាក់ចំនួន ៦,៤៩៨ ដុល្លាអាមេរិក

២. ប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល៖

រដ្ឋាភិបាលចំណាយទឹកប្រាក់អស់ចំនួន២,៤៣៩,៦៣៨ ដុល្លាអាមេរិក និងធុរជនចំណាយទឹកប្រាក់អស់ចំនួន៧,១៩៦ ដុល្លាអាមេរិក។

## ៥. កិច្ចពិគ្រោះយោបល់បឋម(ជាមួយអ្នកពាក់ព័ន្ធ)

ការវិភាគ និងវាយតម្លៃអំពីផលប៉ះពាល់លើសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដូចជា៖

១-ពិភាក្សាជាមួយក្រុម ORIA ប្រចាំECOSSOC នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន៤ដង

២-ពិគ្រោះយោបល់ជាមួយមន្ត្រីមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកែប និងកំពត

៣-ពិគ្រោះយោបល់ជាមួយវិស័យឯកជន (ខេត្តកែប ចំនួន៣៥នាក់ និងខេត្តកំពត ចំនួន៦៥នាក់)៖

- សមាគមអ្នកផលិតអំបិល
- ក្រុមអ្នកផលិតអំបិល
- អ្នកផលិត និងកែច្នៃអំបិល
- អ្នកលក់អំបិល
- អ្នកប្រើប្រាស់អំបិល

## ៦. សន្និដ្ឋាន:

តាមការវិភាគអំពីបន្ទុកចំណាយឃើញថា ជម្រើសទី២ត្រូវបានជ្រើសរើស ដោយបន្ទុកចំណាយរបស់រដ្ឋាភិបាលនៅជម្រើសទី១មានចំនួនទឹកប្រាក់ ២,៤៤៩,២០០ ដុល្លាអាមេរិក និងធុរជនមានចំនួនទឹកប្រាក់ ៦,៤៩៨ ដុល្លាអាមេរិក រីឯបន្ទុកចំណាយរបស់ជម្រើសទី២វិញ រដ្ឋាភិបាលត្រូវចំណាយទឹកប្រាក់ចំនួន ២,៤៣៩,៦៣៨ ដុល្លាអាមេរិក និងធុរជនទឹកប្រាក់ចំនួន ៧,១៩៦ ដុល្លាអាមេរិក។ បើធៀបទៅនិងការចំណាយជម្រើសទី១ និងទី២ ចំណាយរបស់ធុរជនមានចំនួនខុសគ្នាបន្តិចបន្តួច ប៉ុន្តែចំណាយរដ្ឋាភិបាលមានចំនួនទឹកប្រាក់ខុសគ្នាយ៉ាងខ្លាំងគួរឱ្យគត់សម្គាល់ ។

## ៧. ការអនុវត្ត និងការតាមដាន:

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើស អ្នកផលិតអំបិលនឹងទទួលបានការលើកទឹកចិត្ត ទទួលការគាំទ្រផ្នែកបច្ចេកទេសផលិត និងកែច្នៃអំបិល។ ម្យ៉ាងអំបិលដែលផលិតបាន មានស្តង់ដារគុណភាពដែលអាចប្រកួតប្រជែងទីផ្សារជាតិ និងអន្តរជាតិ។ បញ្ញត្តិកម្មនេះ គួរធ្វើការពិនិត្យ ឬតាមដានរយៈពេល ៣ ទៅ ៥ឆ្នាំម្តង។

# ការវាយតម្លៃបឋមលើផលប៉ះពាល់

| | |
|---|---|
| ចំណងជើងបញ្ញត្តិកម្ម: | សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល |
| ក្រសួង: | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| លេខយោង: | ឧ.ស.ហ/០០១ |
| កាលបរិច្ឆេទចាប់ផ្តើម : | [ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦] |
| កាលបរិច្ឆេទបញ្ចប់ : | [ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៦] |

## អត្ថាធិប្បាយសង្ខេបអំពីសំណើប្រកាស

សេចក្តីព្រាងប្រកាសនេះមានគោលបំណង គ្រប់គ្រងស្រែអំបិល ផលិតកម្មអំបិល និងផលិតផលអំបិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឱ្យបាននូវសុវត្ថិភាព គុណភាព និរន្តភាពនៃផលិតកម្ម និងអភិវឌ្ឍផលិតភាពអំបិលឆ្ពោះទៅរកការប្រកួតប្រជែងនៅលើទីផ្សារជាតិ និងអន្តរជាតិ ក៏ដូចជាចូលរួមលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងសេដ្ឋកិច្ចជាតិផងដែរ និងទប់ស្កាត់ការបោះបង់ការផលិតអំបិលដោយទុកដីស្រែអំបិលឱ្យនៅទំនេរ និងការកែប្រែដីស្រែអំបិលទៅមុខសញ្ញាផ្សេង។

រំលិចៈយោងលើច្បាប់អី គោលបំណង វិសាភាព កាតព្វកិច្ច

## ប្រភេទបញ្ញត្តិកម្ម

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☐ | ☑ | ☐ | ☐ | ☐ |

ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ ៖

☑ **សេដ្ឋកិច្ច** ☐សង្គមកិច្ច ☐បរិស្ថាន ☐សុខភាពសាធារណៈ:

## ១. ការកំណត់បញ្ហា

១.១. បញ្ហាចម្បងដែលប្រកាសមានបំណងដោះស្រាយ ដោយផ្តល់អំណះអំណាង

-ស្រែអំបិល និងសិប្បកម្មអំបិលនៅព្រះរាជាណាចក្រកម្ពុជានៅពុំទាន់មានបែបបទ និងនីតិវិធីនៃការគ្រប់គ្រងឱ្យបានច្បាស់លាស់នៅឡើយ។

-ដីស្រែអំបិលនិងការផលិតអំបិលមិនទាន់មានការគ្រប់គ្រងប្រកបដោយបប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព ធ្វើឱ្យមានបញ្ហាប្រឈមនូវសកម្មភាពអាណាធិបតេយ្យជីកដី ឬចាក់ដី ប្តូបបំពេញនៅតំបន់ដីស្រែអំបិល និងតំបន់មានសក្តានុពលអំបិល។

-សិប្បករមួយចំនួនបានបោះបង់ចោលការផលិតអំបិលដោយទុកដីស្រែអំបិលឱ្យនៅទំនេរ និងកែប្រែដីស្រែអំបិលទៅជាមុខសញ្ញាផ្សេងៗ។

-អំបិលក្នុងប្រទេសកម្ពុជាដែលផលិតបានកន្លងមកមិនទាន់មានការវេចខ្ចប់ឱ្យបានត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស និតស្តង់ដារនៅឡើយ ដែលធ្វើឱ្យអំបិលនោះមានសភាពកខ្វក់ និងមិនអាចធ្វើការនាំចេញបាននៅឡើយ។
-អ្នកវិនិយោគ និងអ្នកប្រើប្រាស់មិនទាន់មានទំនុកចិត្តក្នុងការប្រើប្រាស់អំបិលនៅឡើយ ជាហេតុធ្វើឱ្យទីផ្សារអំបិលក្នុងប្រទេសកម្ពុជាមានការធ្លាក់ចុះ។ ម្យ៉ាងទៀតអំបិលមួយចំនួនដែលបានផលិត មិនទាន់មានសាធាតុអ៊ីយ៉ូតគ្រាប់គ្រាន់សម្រាប់ជំនួយដល់សារពាង្គកាយមនុស្សនៅឡើយ (តាមរបាយការណ៍របស់អង្គការ UNICEF កាលពីឆ្នាំ២០១៥)។

១.២. បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលប្រកាសអាចជួយដោះស្រាយផងដែរ ដោយផ្តល់អំណះអំណាង

១.៣. សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល។

**១.ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ៖** មាត្រា១ មាត្រា២ និងមាត្រា២៣ ចែងអំពីស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ប្រភេទរោងចក្រ-សិប្បកម្ម និងដើម្បីឱ្យការបង្កើតរោងចក្រ-សិប្បកម្មមួយស្រប់ច្បាប់ តម្រូវម្ចាស់រោងចក្រ-សិប្បកម្ម ធ្វើការចុះបញ្ជីជាមុននៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត។
**២.អនុក្រឹត្យស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ ៖** មាត្រា២ និងមាត្រា៣ ចែងពីការលុបបំបាត់កង្វះជាតិអ៊ីយ៉ូដ និងបានតម្រូវឱ្យជនគ្រប់រូប ភោជនីយដ្ឋានទាំងអស់ រោងចក្រ សហគ្រាស សិប្បកម្ម មន្ទីរពេទ្យ និងគ្រប់កន្លែងដែលរៀបចំអាហារួម ត្រូវប្រើអំបិលអ៊ីយ៉ូដក្នុងការផលិតម្ហូបអារហារនំចំណីសម្រាប់បរិភោគ។
**៣.ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារចុះបញ្ជីសិប្បកម្មផលិតអំបិល ៖** មាត្រា១ និងមាត្រា២ ចែងអំពីការធ្វើប្រតិភូកម្មមុខងារចុះបញ្ជីសិប្បកម្មស្រែអំបិលទៅថ្នាក់ក្រោមជាតិ និងដើម្បីសម្រួលដល់ការផ្តល់សេវាសាធារណៈជូនម្ចាស់សិប្បកម្មផលិតអំបិល។

**ដោយលិខិតបទដ្ឋានទាំងបីខាងលើនេះ ជាលិខិតគោល និងពុំមានកំណត់ពីបែបបទ និងនីតិវិធីលម្អិតច្បាស់លាស់ក្នុងការគ្រប់គ្រងស្រែអំបិលនៅឡើយ ទើបក្រសួងបានរៀបចំតាក់តែងនូវសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល ដើម្បីកំណត់បែបបទ និងនីតិវិធីច្បាស់លាសក្នុងការគ្រប់គ្រងស្រែអំបិលក្នុងព្រះរាជាណាចក្រកម្ពុជាកុំឱ្យមានការលុបបំបាត់ដីស្រែអំបិល និងការធ្វើអាជីវកម្មអំបិលខុសច្បាប់។**

១.៤. តើសំណើប្រកាសមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?

ពុំមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងទេ។

## ២. គោលបំណង - តើយើងចង់សម្រេចបានអ្វី?

| |
|---|
| ១. ការគ្រប់គ្រងស្រែអំបិលជាលក្ខណៈប្រព័ន្ធ<br>២. លើកកម្ពស់ផ្នែកបច្ចេកទេសដល់ការផលិត និងកែច្នៃអំបិល<br>៣. បង្កើន និងពង្រឹងការប្រកួតប្រជែងទាំងថ្នាក់ជាតិ និងអន្តរជាតិ ។ |

## ៣. ជម្រើស

## ជម្រើសផ្សេងៗរួមទាំងសំណើបញ្ញត្តិកម្ម

| |
|---|
| ១.រក្សាស្ថានភាពដើម<br>២.សំណើបញ្ញត្តិកម្ម : សេចក្ដីព្រាងប្រកាសស្ដីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល |

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគព្វកិច្ច និងផលចំណេញ

៤.១. ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១:<br>រក្សាស្ថានភាពដើម | ១. លើកលែងពន្ធនាំចូលម៉ាស៊ីនបញ្ចូលសារធាតុអ៊ីយ៉ូដ ១០០% (ម៉ាស៊ីនធំ និងមធ្យម)<br><br>២.លើលែងសួយសារអាករ<br>៣.តម្លៃដីដែលរដ្ឋប្រគល់ឱ្យអ្នកសិប្បករ<br>៤.លើកលែងពន្ធនាំចូលសារធាតុអ៊ីយ៉ូដ ១០០% | ១.ស្នើសុំការអនុញ្ញាតផ្សេងៗសំរាប់ដំណើរការសិប្បកម្ម<br>-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>-ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងពាណិជ្ជកម្ម<br>-មន្ទីរពាណិជ្ជកម្មខេត្ត<br>-មន្ទីរឧស្សាហកម្ម រ៉ែនិងថាមពល និងមន្ទីរពាណិជ្ជកម្មខេត្ត<br>-អាជ្ញាធរដែនដី<br>-អាជ្ញាធរដែនដី និងមន្ទីរពាណិជ្ជកម្មខេត្ត<br>-ផ្សេងៗ |
| ជម្រើសទី២:<br>សំណើបញ្ញកម្មៈ<br>ប្រកាសស្ដីពីការ | ១. ពិគ្រោះយោបល់<br>-ប្រាក់បេសកកម្ម (មន្ត្រីក្រសួង)<br>-ប្រាក់បេសកកម្ម (មន្ត្រីថ្នាក់ខេត្ត) | ១.ស្នើសុំចុះបញ្ជីឧស្សាហកម្ម<br>-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម |

| | | |
|---|---|---|
| គ្រប់គ្រងស្រែ<br>អំបិលនិង<br>ផលិតកម្មអំបិល | -មធ្យោបាយធ្វើដំណើរ (ឡាន)<br>-មធ្យោបាយធ្វើដំណើរ (ម៉ូតូ)<br>២. ផ្សព្វផ្សាយប្រកាស<br>-ប្រាក់បេសកកម្ម<br>-មធ្យោបាយធ្វើដំណើរ (ឡាន)<br>៣. ជំនួយបច្ចេកទេសដើម្បីផលិតអំបិល<br>-ការបណ្តុះបណ្តាល<br>-មធ្យោបាយធ្វើដំណើរ<br>៤.ការស្វែងរកទីផ្សារ<br>-សិក្ខាសាលាតាមតំបន់ដែលផលិត<br>អំបិល<br>+អាហារសម្រន់<br>+Backdrop<br>៥.កាត់បន្ថយពន្ធនាំចូលម៉ាស៊ីនអ៊ីយ៉ូដ<br>៦.តម្លៃដីដែលរដ្ឋប្រគល់ឱ្យអ្នកសិប្បករ<br>៧.លើកលែងពន្ធនាំចូលសារធាតុអ៊ីយ៉ូដ<br>១០០% | ២.ប្រកាសបង្កើត និងវិញ្ញាបនបត្រដំណើរការ<br>-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |

៤.២. ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| ជម្រើសទី១:<br>រក្សាស្ថានភាពដើម | -ម្ចាស់សិប្បកម្មអាចគ្រប់គ្រងស្រែអំបិលដោយខ្លួនឯងបាន<br>-បានទទួលនូវចំណេះដឹងកាន់តែច្បាស់ពីសារៈសំខាន់អំបិល<br>-អាចធ្វើការវេចខ្ចប់អំបិលដោយខ្លួនឯងបាន<br>-មិនចាំបាច់ចុះបញ្ជីក្នុងការធ្វើអាជីវកម្មរបស់ខ្លួន<br>-ចំណេញពេលវេលារកស៊ី<br>-មិនចំណាយថវិការសម្រាប់ការចុះបញ្ជី |
| ជម្រើសទី២: | - បង្កើតភាពច្បាស់លាស់ ប្រាកដនិយមនៃនីតិវិធី<br>- បង្កើនទំនុកចិត្តដល់ធុរជន និងអ្នកប្រើប្រាស់<br>- ទាក់ទាញការវិនិយោគ និងបង្កើតទីផ្សារអំបិល |

| | |
|---|---|
| សំណើបញ្ញត្តិកម្ម : សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិលនិងផលិតកម្មអំបិល | - បង្កើនសមត្ថភាពប្រកួតប្រជែង ទាំងក្នុងប្រទេស និងអន្តរជាតិ<br>- បង្កើតការងារជូនប្រជាពលរដ្ឋ<br>- លើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ<br>- បង្កើនប្រសិទ្ធភាពដល់ការគ្រប់គ្រង និងការអភិវឌ្ឍន៍អំបិលប្រកបដោយចីរភាព<br>-ទប់ស្កាត់ការយកដីស្រែអំបិលទៅប្រើប្រាស់ក្នុងកម្មវត្ថុផ្សេង<br>-ដោះស្រាយភាពអសកម្មបានទាន់ពេលវេលា និងចំគោលដៅ។ |

៤.៣. វិសាលភាពនជម្រើសនីមួយៗ

| ជម្រើស | វិស័យ ឬប្រភេទធុរជន | ចំនួនធុរជន | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១: រក្សាស្ថានភាពដើម | សហគ្រាសផលិតអំបិល | ១០០ | របាយការណ៍..........<br>សេចក្តីថ្លែងការ<br>អ្នកនាំពាក្យក្រសួង |
| ជម្រើសទី២:សេចក្តីព្រាងប្រកាស ស្តីពីការគ្រប់គ្រងស្រែអំបិលនិងផលិតកម្មអំបិល | ស្រែអំបិល ការកែច្នៃអំបិល(SME) | ប្រហែល ៣០០គ្រួសារ | តារាងស្ថិតិស្រែអំបិល និងគ្រួសារដែលមានដីស្រែអំបិល |

## ៥. កិច្ចពិគ្រោះយោបល់បឋម(ជាមួយអ្នកពាក់ព័ន្ធ)

ការវិភាគ និងវាយតម្លៃអំពីផលប៉ះពាល់លើសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិលនិងផលិតកម្មអំបិល ក្រុមការងារវាយតម្លៃផលប៉ះពាល់ លិខិតបទដ្ឋានគតិយុត្តក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដូចជា៖

១-ពិភាក្សាជាមួយក្រុម ORIA ប្រចាំECOSSOC នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន៤ដង
២-ពិគ្រោះយោបល់ជាមួយមន្ត្រីមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកែប និងកំពត
៣-ពិគ្រោះយោបល់ជាមួយវិស័យឯកជន (ខេត្តកែប ចំនួន៣៥នាក់ និងខេត្តកំពតចំនួន ៦៥នាក់)៖

- សមាគមន៍អ្នកផលិតអំបិល
- ក្រុមអ្នកផលិតអំបិល
- អ្នកផលិតនិងអ្នកកែច្នៃអំបិល
- អ្នកលក់អំបិល
- អ្នកផលិតអំបិល

## ៦. សន្និដ្ឋាន

តាមការវិភាគអំពីបន្ទុកចំណាយឃើញថា ជម្រើសទី២ត្រូវបានជ្រើសរើស ដោយបន្ទុកចំណាយរបស់រដ្ឋាភិបាលនៅជម្រើសទី១មានចំនួនទឹកប្រាក់ ២,៤៩៩,២០០ ដុល្លាអាមេរិក និងធុរជនមានចំនួនទឹកប្រាក់ ៦,៤៩៨ ដុល្លាអាមេរិក រីឯបន្ទុកចំណាយរបស់ជម្រើសទី២វិញ រដ្ឋាភិបាលត្រូវចំណាយទឹកប្រាក់ចំនួន ២,៤៣៩,៦៣៨ ដុល្លាអាមេរិក និងធុរជនទឹកប្រាក់ចំនួន ៧,១៩៦ ដុល្លាអាមេរិក។ បើធៀបទៅនិងការចំណាយជម្រើសទី១ និងទី២ ចំណាយរបស់ធុរជនមានចំនួនខុសគ្នាបន្តិចបន្តួច ប៉ុន្តែចំណាយរដ្ឋាភិបាលមានចំនួនទឹកប្រាក់ខុសគ្នាយ៉ាងខ្លាំងគួរឱ្យគត់សម្គាល់ ។

.តើចាំបាច់ធ្វើ RIS ដែរឬទេ?

☐ចាំបាច់

☑មិនចាំបាច់

**អំណះអំណាង**

យោងទៅតាមការវិភាគអំពីបន្ទុកចំណាយនៃជម្រើសទី១ និងទី២ នៃការវាយតម្លៃបឋមលើផលប៉ះពាល់ (PAS) នេះ ឃើញថា មិនចាំបាច់ត្រូវធ្វើការវាយតម្លៃពេញលេញលើផលប៉ះពាល់ (RIS) ព្រោះបន្ទុកចំណាយទាបសំរាប់ធុរកិច្ច។

## ៧. ការអនុវត្ត និងការតាមដាន

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើស៖

៧.១.តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើស អ្នកផលិតអំបិលនឹងការលើកទឹកចិត្តដល់ការផលិត បានទទួលការគាំទ្រផ្នែកបច្ចេកទេសផលិត និងកែច្នៃអំបិល។ ម្យ៉ាងអំបិលដែលផលិតបាន មានស្តង់ដារគុណភាពដែលអាចប្រកួតប្រជែងទីផ្សារជាតិ និងអន្តរជាតិ។

៧.២. តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ/តានដានយ៉ាងដូចម្តេច និងនៅពេលណា?

បញ្ញត្តិកម្មនេះ គួរធ្វើការពិនិត្យ ឬតាមដានរយៈពេល ៣ ទៅ ៥ឆ្នាំម្តង។

**អត្ថាធិប្បាយផ្សេងទៀត**

Attached:

Annex 1: CBA

Annex 2: Survey

| ដំណើរការ | ឈ្មោះ | មុខងារ | ទំនាក់ទំនង |
|---|---|---|---|
| **រៀបចំដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម** | ១.លោក ចាតស្វ សុភ័ក្រ | **ប្រធាន** | ០១២ ៣១០ ០១៣ |
| | ២.លោក ឡៅ សត្យា | **អនុប្រធាន** | ០១៧ ៥២៨ ១៨៣ |
| | ៣.លោកស្រី សេង ស៊ីណា | **សមាជិក** | ០១៧ ៨៤៤ ០៩៧ |
| | ៤.លោក ថាច់ កេត | **សមាជិក** | ០៧៧ ៨៨៤ ៥៨៤ |
| ផ្តល់យោបល់ដោយ ក្រុម RIA របស់ ECOSOCC៖ | ឯ.ឧ ប៊ិច សុខា | អ្នកគ្រប់គ្រងគម្រោងRIA | ០១២ ៦៩៨ ៩៩៩ |
| | ឯ.ឧ អេង វត្ថមុន្នី | ប្រធានក្រុម២ ផ្នែកបណ្តុះបណ្តាល និងសម្របសម្រួល | ០១២ ៩១២ ០០៩ |
| | ឯ.ឧ សំ សំណាង | សមាជិកក្រុម៣ | ០៧៧ ៦៨៨ ០៩៥ |
| | លោក អ៊ុំ វិចិត្រ | សមាជិកក្រុម៣ | ០១១ ២១៧ ៧១៧ |
| ជំនួយការ | កញ្ញា ឡាំ វិចហ្វង | បុគ្គលិករដ្ឋបាល | ០៨៩ ៣៨៨ ៧៨៧ |
| | លោក ហាង្ស ពិសិដ្ឋ | បុគ្គលិករដ្ឋបាល | ០៨៩ ៦៩៦ ៦១១ |
| បញ្ចូលទៅក្នុង Database | | | |